ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ០៤ .សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការសិក្សាស្រាវជ្រាវប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករ និយោជិត ផ្នែកវាយនភ័ណ្ឌ កាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០៣៩៧/០១ ចុះថ្ងៃទី ១៣ ខែមីនា ឆ្នាំ១៩៩៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការងារ
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

## សម្រេច

**ប្រការ ១.-**

ត្រូវបានបង្កើតគណៈកម្មការសិក្សាស្រាវជ្រាវស្តីពីប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករ និយោជិត ផ្នែកវាយនភ័ណ្ឌ កាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើង ដែលមានសមាសភាពដូចខាងក្រោមៈ

| | |
|---|---|
| ១- ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ | ប្រធាន |
| ២- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | អនុប្រធាន |
| ៣- តំណាងក្រសួងមហាផ្ទៃ | អនុប្រធាន |
| ៤- តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | អនុប្រធាន |
| ៥- តំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |

www.pheakdeylaw.com

៦- តំណាងក្រសួងសង្គមកិច្ច និងអតីតយុទ្ធជន សមាជិក

៧- តំណាងក្រសួងពាណិជ្ជកម្ម សមាជិក

៨- តំណាងឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ សមាជិក

៩- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក

១០- តំណាងសភាពាណិជ្ជកម្មកម្ពុជា សមាជិក

១១- គណៈកម្មការប្រឹក្សាការងារ សមាជិក

**ប្រការ ២.-**

គណៈកម្មការនេះមានតួនាទី និងភារកិច្ច ដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវកត្តាគន្លឹះសំខាន់ៗជាមូលដ្ឋាន ក្នុងការរៀបចំប្រាក់ឈ្នួលអប្បបរមា សម្រាប់កម្មករ និយោជិត ផ្នែកវាយនភណ្ឌ កាត់ដេរសំលៀកបំពាក់ និងផលិតស្បែកជើង ។
- សហការជាមួយដៃគូអភិវឌ្ឍន៍ទាំងរដ្ឋាភិបាល និងវិស័យឯកជននានាដែលពាក់ព័ន្ធ។
- ផ្ដល់ជម្រើសស្ដីពីការរៀបចំកម្រិតប្រាក់បៀវត្សអប្បបរមារយៈពេលខ្លី មធ្យម និងរយៈពេលវែង ជូនរាជរដ្ឋាភិបាលដើម្បីពិនិត្យសម្រេច ។

**ប្រការ ៣.-**

គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់មន្ត្រីជំនាញក្រោមឱវាទជាជំនួយការ ។

**ប្រការ ៤.-**

ឯកឧត្តម គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ចនិងអតីតយុទ្ធជន រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ប្រធានសភាពាណិជ្ជកម្មកម្ពុជា គណៈកម្មការប្រឹក្សាការងារ និងប្រធានស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តតាមសេចក្ដីសម្រេចនេះឲ្យទទួលបានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ៕

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែមករា ឆ្នាំ២០១៤

នាយករដ្ឋមន្ត្រី

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**<u>កន្លែងទទួល៖</u>**

- ក្រសួងព្រះបរមរាជវាំង
- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ ៤
- ឯកសារកាលប្បវត្តិ



www.pheakdeylaw.com